អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens
អង្គភាពគាំពារជនរងគ្រោះ
Victims Support Section
Section d'appui aux victimes

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ភ្នំពេញ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## អង្គភាពគាំពារជនរងគ្រោះនឹងរៀបចំវេទិកាថ្នាក់តំបន់លើកទី៤ ឆ្នាំ២០១២ នៅខេត្តព្រះសីហនុ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២

អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងរៀបចំវេទិកាថ្នាក់តំបន់លើកទី៤ ក្នុងឆ្នាំ២០១២ នៅខេត្តព្រះសីហនុ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២០០ នាក់ ក្នុងសំណុំរឿង ០០២។ វេទិកាថ្នាក់តំបន់នេះនឹងធ្វើនៅសណ្ឋាគារឆ្នេរជលសារ ***នៅថ្ងៃសុក្រ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ វេលាម៉ោង ៨:០០ព្រឹក ដល់ម៉ោង ៤:០០ រសៀល***។ *(អត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវរក្សាជាសម្ងាត់)* ។

វេទិកាថ្នាក់តំបន់នេះមានគោលបំណង (១) ផ្តល់ព័ត៌មានថ្មីៗអំពីដំណើរវិវឌ្ឍន៍របស់ អ.វ.ត.ក ទាក់ទងនឹងសំណុំរឿង០០២ ដល់ដើមបណ្តឹងរដ្ឋប្បវេណី (២) ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីទទួលបានការពន្យល់ពីមេធាវីរបស់ខ្លួននូវដំណើការនៃការបំបែកនីតិវីធីសំណុំរឿង ០០២ ដែលកំពុងជម្រះក្តីជាផ្នែកតូចៗដាច់ពីគ្នានិង (៣) ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះប្រើប្រាស់សិទ្ធិរបស់ខ្លួន។

ដើមបណ្តឹងរដ្ឋប្បវេណីទាំង ២០០នាក់ ធ្វើដំណើរមកពីខេត្តព្រះសីហនុ កំពត កោះកុង និងកំពង់ស្ពឺ និងស្ថិតក្នុងចំណោម ដើមបណ្តឹងរដ្ឋប្បវេណីទាំង ៣ ៨៦៤ នាក់ ដែលមិនធ្លាប់បានចូលរួមស្តាប់សវនាការនៃសំណុំរឿង០០២ ក្នុងឆ្នាំ២០១២ នេះទេ។ វេទិកាថ្នាក់តំបន់នេះនឹងផ្តល់ឱកាសពិសេសសម្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីទាំង ២០០នាក់ បាន ជួបគ្នាដើម្បីពិភាក្សាពន្យល់អំពីដំណើរវិវឌ្ឍន៍របស់សំណុំរឿង ០០២ និងស្វែងយល់អំពីដំណាក់កាលដែលដើមបណ្តឹងរដ្ឋប្បវេណី ទទួលរងគ្រោះដោយឧក្រិដ្ឋកម្មផ្សេងៗគ្នា ត្រូវចូលរួមនៅក្នុងដំណើរការជំនុំជម្រះសេចក្តីជាផ្នែកតូចៗនេះ។

អង្គភាពគាំពារជនរងគ្រោះមានផែនការរៀបចំវេទិកាថ្នាក់តំបន់ចំនួន ៨ ក្នុងឆ្នាំ២០១២-២០១៣ ក្នុងគម្រោង "ការចូលរួមរបស់ជនរងគ្រោះប្រកបដោយអត្ថន័យក្នុងដំណើការនីតិវិធី អ.វ.ត.ក"។ ចន្លោះឆ្នាំ ២០០៩-២០១១ អង្គភាពគាំពារជនរងគ្រោះបានរៀបចំវេទិកាថ្នាក់តំបន់ចំនួន ១៤ ក្នុងក្របខ័ណ្ឌគម្រោង "ការធ្វើឲ្យប្រសើរឡើងដល់ការចូលរួមរបស់ជនរងគ្រោះក្នុងដំណើការនីតិវិធី អ.វ.ត.ក"។

---

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖
លោក អ៊ឹម សុភា, មន្ត្រីទទួលបន្ទុកនៃអង្គភាពគាំពារជនរងគ្រោះ
ទូរស័ព្ទចល័ត: ០៧៧ ៧៧៧ ៣៦៧, អ៊ីម៉ែល: im.sophea@eccc.gov.kh